01045596

ឯកសារដើម
ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/date de reception):
11 / 12 / 2014
ម៉ោង (Time/Heure) : 9:30
មន្ត្រីទទួលបន្ទុកសំណុំរឿង /Case File Officer/L'agent chargé du dossier: SANN RADA

លេខ / N°: C1

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**Kingdom of Cambodia**
**Nation Religion King**
**Royaume du Cambodge**
**Nation Religion Roi**

**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
Extraordinary Chambers in the Courts of Cambodia

**ការិយាល័យសហចៅក្រមស៊ើបអង្កេត**
**Office of the Co-Investigating Judges**
**Bureau des Co-juges d'instruction**
**សំណុំរឿងព្រហ្មទណ្ឌ**
**Criminal Case File /Dossier pénal**
**លេខ/No:003/07-09-2009-ECCC-OCIJ**

# ដីកាបង្គាប់ឱ្យនាំខ្លួន
# Arrest Warrant
# Mandat d'amener

ខ្ញុំ **Mark B. Harmon** សហចៅក្រមស៊ើបអង្កេតអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(“អ.វ.ត.ក”)

**បានឃើញ** ច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា ចុះថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០០៤(“ច្បាប់ស្តីពីការបង្កើត អ.វ.ត.ក”)។

**បានឃើញ**វិធាន ១១, ១៥, ២១, ២២,៤១, ៤២, ៤៥, ៥១, ៥៥, ៥៧ និង៧២ នៃវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក (“វិធានផ្ទៃក្នុង”)។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២ របស់សហព្រះរាជអាជ្ញាទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩[1]។

**បានឃើញ** *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង ០០៣* ដាក់នៅថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២០១៤(“ដីកាសន្និដ្ឋានបញ្ជូនឱ្យស៊ើបសួរបន្ថែម”[2]។

---

[1]សំណុំរឿង ០០៣ ឯកសារ D1 *ដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលើកទី២របស់សហព្រះរាជអាជ្ញា ទាក់ទងនឹងកងទ័ពបដិវត្តន៍កម្ពុជា* ដាក់នៅថ្ងៃទី ៧ ខែ កញ្ញា ឆ្នាំ ២០០៩។

**បានឃើញ** កិច្ចស៊ើបសួរទាក់ទងនឹងការចោទប្រកាន់អំពីការរំលោភបំពាន**ក្រមព្រហ្មទណ្ឌ ឆ្នាំ ១៩៥៦ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ** និង**ការរំលោភបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទីក្រុងហ្សឺណែវ ចុះថ្ងៃទី ១២ ខែ សីហា ឆ្នាំ ១៩៤៩** ជាបទល្មើសដែលមានចែង និងផ្តន្ទាទោសតាមមាត្រា ៣(ថ្មី), ៥, ៦, ២៩ និង ៣៩ នៃច្បាប់ស្តីពីការបង្កើត អ.វ.ត.ក និងមាត្រា៥00, ៥0១, ៥0៣, ៥0៥, ៥0៦, ៥0៧ និង ៥0៨ នៃក្រមព្រហ្មទណ្ឌឆ្នាំ ១៩៥៦។

**បានឃើញ**ថា មាស មុត គឺជាជនសង្ស័យម្នាក់ដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរ និងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែម។

**បានឃើញ**កំណត់ហេតុនៃករណីខ្វែងយោបល់គ្នា ចុះបញ្ជើនៅថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២0១៤។

**បានឃើញ**ព័ត៌មានដូចខាងក្រោមទាក់ទងនឹងអត្តសញ្ញាណរបស់មាស មុត៖

ឈ្មោះ៖ **មាស មុត** ហៅ អាចារ្យ នេន

ថ្ងៃខែឆ្នាំកំណើត៖ ១៩៣៨

ស្រុកកំណើត៖ ភូមិពោធិ៍ ឃុំស្រែក្នុង ស្រុកឈូក ខេត្តកំពត

សញ្ជាតិ៖ ខ្មែរ

ទីលំនៅបច្ចុប្បន្ន៖ ភូមិតាសាញ ជើង ស្រុកសំឡូត ខេត្តបាត់ដំបង

ឈ្មោះប្រពន្ធ៖ ខុំ(Khom) (ស្លាប់) និង ខា(Kha)

ឈ្មោះកូន៖ ភាព និងវុធ

មានរូបថតដូចបានភ្ជាប់ជាមួយ។

**បានឃើញ**ថា នៅថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២0១៤ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានចេញដីកាកោះហៅមាស មុត ឲ្យមកបង្ហាញខ្លួននៅ អ.វ.ត.ក សម្រាប់ការបង្ហាញខ្លួនលើកដំបូង នៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២0១៤[3]។

**បានឃើញ**ថា លោក Thomas Kuenel អ្នកស៊ើបអង្កេតនៅ អ.វ.ត.ក បានប្រគល់ដីកាកោះនេះជូនមាស មុត នៅថ្ងៃទី ២៨ ខែ វិច្ឆិកា ឆ្នាំ ២0១៤[4]។

---

[2]សំណុំរឿង 00៣ ឯកសារ D120 *ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរបន្ថែមរបស់សហព្រះរាជអាជ្ញាអន្តរជាតិស្តីពីទីតាំងឧក្រិដ្ឋកម្មនានាទាក់ទងនឹងសំណុំរឿង 00៣* ថ្ងៃទី ៣១ ខែ តុលា ឆ្នាំ ២0១៤។

[3]សំណុំរឿង 00៣ ឯកសារ A66 *ដីកាកោះហៅមាស មុត ឲ្យបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ២៦ ខែ វិច្ឆិកា ឆ្នាំ ២0១៤។

[4]សំណុំរឿង 00៣ ឯកសារ A66/1 *កំណត់ហេតុនៃការប្រគល់ដីកាកោះ* ថ្ងៃទី ៥ ខែ ធ្នូ ឆ្នាំ ២0១៤។

**បានឃើញ**ថា នៅក្នុងលិខិតមួយចុះថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤ មាស មុត បានជូនដំណឹង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ថា គាត់មិនទទួលស្គាល់សុពលភាពនៃដីកាកោះហៅឲ្យបង្ហាញខ្លួនលើកដំបូងដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ឯងនោះទេ[5]។

**បានឃើញ**ថា នៅថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤ សហមេធាវីតំណាងមាស មុត បានជូនដំណឹង សហចៅក្រមស៊ើបអង្កេត ថា កូនក្តីរបស់ខ្លួន មិនមានបំណងអនុវត្តតាមដីកាកោះ ហើយនឹងមិនមានវត្តមាននៅក្នុងការបង្ហាញខ្លួនលើកដំបូងដែលបានគ្រោងទុកនៅថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤ ទេ[6]។

**បានឃើញ**ថា នៅក្នុង*ការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោកមាស មុតមិនទទួលស្គាល់ដីកាកោះ ចុះថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤* សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានរំឭកថា អង្គបុរេជំនុំជម្រះ បានបញ្ជាក់រួចហើយអំពីសុពលភាពនៃដីកាកោះហៅឲ្យបង្ហាញខ្លួនលើកដំបូងដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់ ដរាបណានីតិវិធីដោះស្រាយករណីខ្វែងយោបល់គ្នាដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ៧២ ត្រូវបានអនុវត្ត ហើយរយៈពេល ៣០ ថ្ងៃសម្រាប់បញ្ជូនករណីខ្វែងយោបល់គ្នាទៅដោះស្រាយនៅចំពោះមុខអង្គបុរេជំនុំជម្រះបានកន្លងផុត[7]។

**បានឃើញ**ថា មាស មុត មិនបានមកបង្ហាញខ្លួនសម្រាប់ការបង្ហាញខ្លួនលើកដំបូងនេះ។

**បានឃើញ**ថា សហមេធាវីជាតិរបស់មាស មុត គឺលោក អាង ឧត្តម បានបង្ហាញខ្លួននៅក្នុងការបង្ហាញខ្លួនលើកដំបូងតាមកាលកំណត់ ហើយបានប្រកាសថា មាស មុត បានបដិសេធមិនមកបង្ហាញខ្លួន ដោយហេតុថា គាត់មិនទទួលស្គាល់សុពលភាពនៃដីកាកោះហៅឲ្យបង្ហាញខ្លួនលើកដំបូងដែលចេញដោយសហចៅក្រមស៊ើបអង្កេតតែម្នាក់[8]។

---

[5]សំណុំរឿង ០០៣ ឯកសារ A67/1.1 *សេចក្តីជូនដំណឹងស្តីពីការមិនទទួលស្គាល់ដីកាកោះ* ថ្ងៃទី ២ ខែ ធ្នូ ឆ្នាំ ២០១៤។

[6]សំណុំរឿង ០០៣ ឯកសារA67/1 *សេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ* ថ្ងៃទី ៣ ខែ ធ្នូ ឆ្នាំ ២០១៤។

[7]សំណុំរឿង០០៣ ឯកសារA67/1/1 *ការឆ្លើយតបទៅនឹងសេចក្តីជូនដំណឹងទាក់ទងនឹងសេចក្តីសម្រេចចិត្តរបស់លោក មាស មុត មិនទទួលស្គាល់ដីកាកោះ* ថ្ងៃទី ៤ ខែ ធ្នូ ឆ្នាំ ២០១៤។

[8]សំណុំរឿង ០០៣ ឯកសារ D122 *កំណត់ហេតុនៃការបង្ហាញខ្លួនលើកដំបូង* ថ្ងៃទី ៨ ខែ ធ្នូ ឆ្នាំ ២០១៤។

អាស្រ័យហេតុនេះ **បង្គាប់** នគរបាលយុត្តិធម៌ ឲ្យអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននេះ។

នគរបាលយុត្តិធម៌ មិនត្រូវចូលទីលំនៅដ្ឋានរបស់មាស មុត មុនម៉ោង ៦ ព្រឹក ឬក្រោយម៉ោង ៦ ល្ងាច ហើយ នគរបាលយុត្តិធម៌ ត្រូវជូនដំណឹង សហចៅក្រមស៊ើបអង្កេតអន្តរជាតិ អំពីការលំបាក ណាមួយនៅក្នុងការបំពេញបេសកកម្មនេះ។

នគរបាលយុត្តិធម៌ ត្រូវនាំ មាស មុត មកបង្ហាញខ្លួននៅចំពោះមុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ សម្រាប់ការបង្ហាញខ្លួនលើកដំបូង។ ប្រសិនបើ ដោយសារកាលៈទេសៈ មាស មុត មិនអាចត្រូវបាននាំខ្លួនមកបង្ហាញនៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានភ្លាមៗទេ គាត់ត្រូវដាក់ឲ្យជាប់ឃុំខ្លួនបណ្ដោះអាសន្ននៅក្នុងមន្ទីរឃុំឃាំងបណ្ដោះអាសន្នរបស់ អ.វ.ត.ក នៅពេលណាដែលអាចធ្វើទៅបាន ហើយត្រូវនាំខ្លួនមកបង្ហាញនៅចំពោះមុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើទៅបាន។

មាស មុត មានសិទ្ធិដូចខាងក្រោមដោយអនុលោមតាមវិធានផ្ទៃក្នុង៖

- សិទ្ធិមានមេធាវីការពារតាមការជ្រើសរើសរបស់គាត់ ដូចមានចែងនៅក្នុងវិធានផ្ទៃក្នុង ១១, ២១ និង២២ និងបទបញ្ជារដ្ឋបាលដែលចូលជាធរមាន។
- សិទ្ធិមានវត្តមានរបស់មេធាវីនៅក្នុងអំឡុងពេលនៃការបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធានផ្ទៃក្នុង ៥៧។
- សិទ្ធិនៅស្ងៀមមិនឆ្លើយនឹងសំណួរ អនុលោមតាមវិធានផ្ទៃក្នុង ៥៧។
- សិទ្ធិផ្ដល់ចម្លើយដោយមានកំណត់ហេតុ ដោយមានវត្តមានរបស់មេធាវី នៅក្នុងអំឡុងពេលនៃការបង្ហាញខ្លួនលើកដំបូង អនុលោមតាមវិធានផ្ទៃក្នុង ៥៧ និង
- សិទ្ធិពិគ្រោះជាមួយមេធាវី មុនពេលគាត់ត្រូវបានសួរចម្លើយនៅក្នុងដំណាក់កាលណាមួយនៃការស៊ើបអង្កេតរបស់តុលាការ។

ប្រសិនបើគាត់ត្រូវដាក់ឲ្យជាប់ឃុំខ្លួនបណ្ដោះអាសន្ន ដោយសារថា គាត់មិនអាចត្រូវបាននាំខ្លួនមកបង្ហាញនៅចំពោះមុខ សហចៅក្រមស៊ើបអង្កេតអន្តរជាតិ បានភ្លាមៗទេនោះ គាត់មានសិទ្ធិដូចខាងក្រោមអនុលោមតាមវិធានផ្ទៃក្នុង៖

- សិទ្ធិស្នើសុំជួបមេធាវី ហើយមេធាវីនោះនឹងត្រូវបានជូនដំណឹងអំពីសំណើនេះភ្លាមៗ តាមមធ្យោបាយទាំងអស់ដែលមាន និង

- សិទ្ធិជួបមេធាវីបែបនោះ ឬក៏ប្រសិនបើចំណុចនេះមិនអាចធ្វើបាន គឺត្រូវជួបមេធាវីម្នាក់ដែលផ្តល់ជូនដោយអង្គភាពគាំពារការការពារក្តី ដោយជួបបានរយៈពេលអតិបរមាណ ៣០ (សាបសិប) នាទីមុនពេលគាត់ត្រូវបានបង្ហាញខ្លួននៅចំពោះមុខសហចៅក្រមស៊ើបអង្កេតអន្តរជាតិ។
មេធាវីរូបនេះត្រូវមានសិទ្ធិមានវត្តមាននៅក្នុងអំឡុងពេលនៃការឃុំខ្លួនគ្រប់គ្រងដោយនគរបាល អាស្រ័យតាមលក្ខខណ្ឌតម្រូវរដ្ឋ បាលរបស់មន្ទីរឃុំឃាំងបណ្តោះអាសន្ន។

សហចៅក្រមស៊ើបអង្កេតអន្តរជាតិ ស្នើថា អាជ្ញាធរមានសមត្ថកិច្ចទាំងអស់ ត្រូវផ្តល់ជំនួយណាដែលអាចស្នើសុំដោយនគរបាលយុត្តិធម៌នៅក្នុងការអនុវត្តដីកាបង្គាប់ឲ្យនាំខ្លួននេះ។

រាជធានីភ្នំពេញ ថ្ងៃទី១០ ខែ ធ្នូ ឆ្នាំ ២០១៤

**ចៅក្រម Mark B. Harmon**

**សហចៅក្រមស៊ើបអង្កេតអន្តរជាតិ**

**International Co- Investigating Judge**

**Co-juge d'instruction International**